HEAD LICE TREATMENT OPTIONS
INFORMATION FOR PARENTS AND CARERS
KHMER

# ជម្រើសនៃការព្យាបាលចៃក្បាល

ព័ត៌មានសម្រាប់មាតាបិតា និងអ្នកថែទាំ

## មានជម្រើសនៃការព្យាបាលចៃក្បាលចំនួនពីរ។

1. ការយកចេញដោយប្រើដៃ (ការយកចេញដោយប្រើស្និតសិតចៃ)
2. ការយកចេញដោយប្រើជាតិថ្នាំគីមី

### ការយកចេញដោយប្រើដៃ

ការយកចេញដោយប្រើដៃ ទាក់ទិននឹងការលាបថ្នាំបន្ទន់សក់ធម្មតាទៅសក់ស្ងួត។ ក្រោយពីបានលាប ហើយញីគ្រប់សរសៃសក់ជាមួយថ្នាំបន្ទន់សក់ហើយ ចូររំដោះសក់ជំពាក់ដោយប្រើក្រាសសិតសក់ធម្មតា រួចហើយ បែងចែកសក់ជាផ្នែកតូចៗ។ បន្ទាប់មកចូរប្រើស្និតសិតចៃធ្មេញវែងធ្វើពីដែក សិតចូកផ្នែកសក់ទាំងនោះ ថ្នាំបន្ទន់សក់ពុំសម្លាប់ចៃទេ ក៏ប៉ុន្តែវាធ្វើឲ្យចៃទៅជាស្រឡាំងកាំងប្រហែល២០នាទីដែលងាយស្រួលនឹងសិតយកវាចេញ។ ស្និតសិតចៃនឹងសិតជំរុះពងចៃ ហើយធ្វើឲ្យចៃទៅជាស្រឡាំងកាំង។ ជូតកៀរស្និតសិតចៃនៅលើក្រដាសសម្រាប់ជូតពណ៌ស ហើយឆែករកមើលចៃ ឬពងចៃណាមួយ។ បន្តការសិតរហូតទាល់តែលែងឃើញមាននៅលើក្រដាសពណ៌ស។ គួរប្រើវិធីនេះរៀងរាល់ពីរថ្ងៃម្តង រហូតទាល់តែពុំមាននៅសល់(ជាទូទៅប្រហែលពី៧ ទៅ១០ថ្ងៃ)។

នេះជាវិធីព្យាបាលចៃក្បាលដែលគេចូលចិត្ត ដោយព្រោះថាវាមានប្រសិទ្ធិភាព មិនជួយផ្តល់ការធន់នឹងថ្នាំពុលដល់ចៃក្បាល ថែមទាំងមានគ្រោះថ្នាក់តិចនៃការកើតមានការរលាកស្បែកទៀតផង។

វិធីយកចេញដោយប្រើដៃក៏ជួយគ្រប់គ្រងចៃក្បាលផងដែរ មុនវាចាប់ផ្តើមពង និងបង្កើតកូននៅលើក្បាល។ សូមរក្សាទុកស្និតសិតចៃក្បាលដែលល្អស្អាតនៅកន្លែងងូតទឹកផ្កាឈូក ហើយរៀងរាល់ពេលដែលក្រុមគ្រួសាររបស់លោកអ្នកលាងសំអាតសក់របស់គេ សូមសិតសក់ឲ្យបានសព្វទីកន្លែងដោយប្រើស្និតសិតចៃ។ ការនេះដើម្បីឲ្យបានប្រាកដច្បាស់ថាលោកអ្នកសិតបានចៃមុននឹងវាចាប់ផ្តើមពងចំនួនយ៉ាងច្រើន។

ប្រសិនបើកូនរបស់លោកអ្នកធំល្មមនឹងចេះលាងសំអាតសក់របស់គេ សូមលើកទឹកចិត្តគេឲ្យប្រើក្រាសសិតសក់ដោយខ្លួនគេ។ បើពុំដូច្នោះទេ សូមរក្សាទុកក្រាសសិតសក់នៅក្បែរកន្លែងដែលលោកអ្នកលាងសំអាតសក់របស់កូនលោកអ្នក ហើយប្រើវារៀងរាល់ពេលដែលលោកអ្នកលាងសំអាតសក់របស់គេ។

### ការយកចេញដោយប្រើជាតិថ្នាំគីមី

ប្រសិនបើលោកអ្នកជ្រើសរើសប្រើការព្យាបាលដោយប្រើជាតិថ្នាំគីមី សូមចងចាំធ្វើតាមការណែនាំដោយប្រុងប្រយ័ត្ន។ កុំព្យាយាមអនុវត្តការព្យាបាលដោយប្រើជាតិថ្នាំគីមីដដែលៗម្តងទៀត ប្រសិនបើវាហាក់បីដូចជាពុំមានប្រសិទ្ធិភាពទេ។ ជាជំនួសវិញនោះ សូមផ្លាស់ប្តូរទៅការព្យាបាលផ្សេងទៀតដែលប្រើសមាសធាតុថ្នាំគីមីខុសគ្នា ឬអនុវត្តវិធីប្រើស្និតសិតចៃ និងថ្នាំបន្ទន់សក់។ លោកអ្នកត្រូវប្រើវិធីព្យាបាលម្តងទៀតក្នុងរយៈពេល៧ថ្ងៃ ដើម្បីសម្លាប់ពងចៃថ្មីៗណាមួយដែលទើបញាស់។ លោកអ្នកក៏នឹងត្រូវការប្រើស្និតសិតចៃផងដែរ ដើម្បីឲ្យបានប្រាកដច្បាស់ថាការព្យាបាលវាមានប្រសិទ្ធិភាព។ ប្រសិនបើលោកអ្នករកឃើញចៃងាប់ បានន័យថាផលិតផលនោះវាមានប្រសិទ្ធិភាព។ ប្រសិនបើលោកអ្នករកឃើញចៃវានៅរស់ បានន័យថាផលិតផលនោះវាពុំមានប្រសិទ្ធិភាពទេ។

ពេលណាកូនរបស់លោកអ្នកលែងមានចៃ និងពងចៃហើយ ចូរចងចាំដើម្បីឆែកមើលឲ្យបានទៀងទាត់ដោយប្រើស្និតសិតចៃ និងថ្នាំបន្ទន់សក់។ ការរកឃើញ និងការព្យាបាលបានទាន់ពេល នឹងបង្ការនូវការកើតមានចៃក្បាលពាសពេញឡើងវិញដល់ក្រុមគ្រួសារ និងសិស្សរួមថ្នាក់។

### តើត្រូវធ្វើអ្វីខ្លះអំពីគ្រែ និងសម្លៀកបំពាក់

ការស្រាវជ្រាវបានស្នើយោបល់ថាកម្រាលគ្រែ មួក សម្លៀកបំពាក់ និងគ្រឿងសង្ហារឹម ពុំផ្តល់ទីជម្រក ឬចម្លងចៃក្បាល ឬពងចៃឡើយ ហើយថាវាពុំមានផលប្រយោជន៍អ្វីសោះដែលត្រូវបោកសំអាតវត្ថុទាំងនោះជាជម្រើសនៃការព្យាបាលចៃក្បាល។ ពងចៃ និងចៃអាចរស់នៅតែលើក្បាលមនុស្សប៉ុណ្ណោះ។ វានឹងខ្សោះជាតិទឹក ហើយងាប់ ប្រសិនបើកំចាត់វាចេញពីក្បាល។

ព័ត៌មាននេះសំអាងលើព័ត៌មានដែលបានផ្តល់នៅតាមវិបសាយរបស់ក្រសួងសុខាភិបាលរដ្ឋ NSW ស្តីអំពី Nitbusters។